COUNT US IN
2020

There's Power In Being Counted

ASIAN AMERICANS ADVANCING JUSTICE

COUNTUSIN2020.ORG

# ជំរឿនឆ្នាំ2020៖ រយៈពេលកំណត់

*មានសំណួរមែនទេ? សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍ផ្នែកជំរឿនរបស់យើង តាមលេខ 844-2020-API សម្រាប់ជំនួយគាំទ្រជាភាសាអង់គ្លេស និងភាសាដទៃផ្សេងទៀត។ សូមចូលមើលគេហទំព័រ [www.CountUsIn2020.org/hotline](www.CountUsIn2020.org/hotline) សម្រាប់ព័ត៌មានបន្ថែម។*

| | **ដំណើរកាលនៃការិយាល័យជំរឿន** | **អ្វីដែលអ្នកអាចធ្វើបានដើម្បីជួយដល់ការរាប់ចំនួន (GOTC)** |
|---|---|---|
| **រដូវក្តៅ ឆ្នាំ 2019 - ខែមីនា ឆ្នាំ 2020 --- ការយល់ដឹង និង ការអប់រំ** | | |
| **ខែមករា-ខែវិច្ឆិកា ឆ្នាំ 2019** | ការិយាល័យជំរឿនបើកមណ្ឌលជំរឿនច្រើនជាង 200 ការិយាល័យ។ | ចាប់ផ្តើមយុទ្ធនាការ ការយល់ដឹង និង ការអប់រំ៖ ប្រាប់សហគមន៍របស់អ្នកអំពីជំរឿន និង សារៈសំខាន់នៃការចូលរួម!<br><br>ចែករំលែកព័ត៌មានអំពីឱកាសការងារនៃជំរឿនឆ្នាំ2020 ជាមួយសហគមន៍របស់អ្នក និង ជួយប្រជាជនដាក់ពាក្យ។ |
| **ខែកញ្ញា ឆ្នាំ 2019 បន្តទៅមុខ** | ការិយាល័យជំរឿនជ្រើសរើស និង ជួលបុគ្គលិកបណ្តោះអាសន្នចុះធ្វើជំរឿនតាមសហគមន៍។ | បន្តយុទ្ធនាការការយល់ដឹង និង ការអប់រំ៖ បន្តចែករំលែកឱកាសការងារ និង ផ្តល់ជំនួយក្នុងការបំពេញបែបបទការងារ។ |
| **ខែមករា ឆ្នាំ 2020** | ការរាប់ចាប់ផ្តើមនៅក្នុងរដ្ឋអាឡាស្កា។ | បន្តយុទ្ធនាការការយល់ដឹង និង ការអប់រំ៖<br>• ចែករំលែកការផ្ញើសារ និង ក្រដាស Fact របស់ GOTC។<br>• ទាក់ទងប្រព័ន្ធផ្សព្វផ្សាយ និង ប្រកាសប្រព័ន្ធផ្សព្វផ្សាយសង្គម។<br>• រៀបចំផែនការ និង ព្រឹត្តិការណ៍ផ្សព្វផ្សាយ។<br>• រៀបចំផែនការផ្សព្វផ្សាយ។<br>• ពន្យល់ពីដំណើរការនៃជំរឿនហើយប្រាប់ប្រជាជនពីវិធីក្នុងការឆ្លើយតប។<br><br>រៀបចំផែនការផ្សព្វផ្សាយដោយចុះទៅផ្ទាល់ និង រៀបចំសម្រាប់ដំណាក់កាលបន្ទាប់នៃ GOTC ចាប់ផ្តើមនៅក្នុងខែមីនា - ឱ្យប្រជាជនឆ្លើយតបទៅនឹងជំរឿន។ |

<table>
<tr><th colspan="3">ខែមីនា - ខែឧសភា ឆ្នាំ2020 --- ប្រជាជនឆ្លើយតបទៅនឹងជំរឿន</th></tr>
<tr><td>ថ្ងៃទី 9 ខែមីនា ឆ្នាំ 2020</td><td>ខ្សែបណ្ដាញទូរស័ព្ទឥតគិតថ្លៃនៃជំនួយផ្នែកកម្រងសំណួរការជំរឿនបើក។<br><br>ជំនួយគាំទ្រតាមទូរស័ព្ទត្រូវបានផ្តល់ជូនជាភាសាអង់គ្លេស និងភាសាមិនមែនអង់គ្លេសចំនួន 12 ភាសារួមមានភាសាចិន (ចិនកុកងឺ និងចិនកន្តាំង) ជប៉ុន កូរ៉េ តាហ្គាឡុក និងវៀតណាម។</td><td>បន្តយុទ្ធនាការយល់ដឹង និងអប់រំ និងចែករំលែកព័ត៌មានអំពីខ្សែបណ្ដាញទូរស័ព្ទឥតគិតថ្លៃនៃជំនួយផ្នែកកម្រងសំណួរការជំរឿនដែលពេលនេះបើកហើយ។</td></tr>
<tr><td>ថ្ងៃទី 12-20 ខែមិនា ឆ្នាំ 2020</td><td>ការិយាល័យជំរឿនផ្ញើព័ត៌មានឯកសារតាមប្រៃសណីយ៍ទៅកាន់ក្រុមគ្រួសារទាំងអស់ដែលមានព័ត៌មានអំពីរបៀបឆ្លើយតបនៅលើបណ្ដាញ (រួមទាំង ID ក្រុមគ្រួសារពិសេស) និងធនធានជំនួយផ្នែកភាសា។ វេទិកាការឆ្លើយតបនៅលើបណ្ដាញនឹងផ្សាយបន្តផ្ទាល់នៅពេលនៃការផ្ញើតាមប្រៃសណីយ៍លើកដំបូង។ ការិយាល័យក៏នឹងផ្ញើតាមប្រៃសណីយ៍នូវទម្រង់បែបបទជាក្រដាសទៅកាន់ 20 ភាគរយនៃក្រុមគ្រួសារដែលខ្លួនសង្ស័យថាមានកម្រិតទាបបំផុតនៃការមានលទ្ធភាពចូលប្រើប្រាស់អ៊ីនធឺណិត។</td><td>ជំរុញប្រជាជនឲ្យមានទឹកចិត្តឆ្លើយតបទៅនឹងជំរឿន៖<ul><li>និយាយទៅកាន់សហគមន៍អ្នកអំពីការជំរឿន</li><li>ចែករំលែកក្រដាសខិត្តប័ណ្ណព័ត៌មាន និងសន្លឹកព័ត៌មានអំពីការពិត</li><li>បន្តយុទ្ធនាការបណ្ដាញផ្សព្វផ្សាយ និងបណ្ដាញសង្គម។</li><li>សាកសួរស្ទង់តំបន់ដែលពិបាកនឹងរាប់។</li></ul></td></tr>
<tr><td>ថ្ងៃទី 16 - 24 ខែមីនា ឆ្នាំ 2020</td><td>ការិយាល័យជំរឿននឹងផ្ញើលិខិតរំលឹកទៅគ្រួសារដែលមិនទាន់បានឆ្លើយតប។</td><td rowspan="5">ផ្តល់ជូនប្រជាជននូវព័ត៌មាន និងការគាំទ្រ ដែលពួកគេត្រូវការដើម្បីធ្វើការឆ្លើយតប៖<ul><li>រៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយ។</li><li>ផ្តល់ឱកាសដល់ប្រជាពលរដ្ឋដើម្បីទទួលបានជំនួយក្នុងការឆ្លើយតបទៅនឹងជំរឿន។</li><li>បន្តយុទ្ធនាការផ្សព្វផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។</li></ul>បន្តការផ្សព្វផ្សាយនៅតាមតំបន់ពិបាកៗទៅដល់ តាមរយ:ការគោះទ្វារ ទូរស័ព្ទ និងសកម្មភាពផ្សេងៗទៀត។<br><br>គម្រូយ៖ ប្រសិនជាប្រជាពលរដ្ឋណាម្នាក់មិនស្គាល់ប័ណ្ណសម្គាល់ខ្លួនពិសេសរបស់ពួកគេដើម្បីធ្វើការឆ្លើយតបតាមប្រព័ន្ធអ៊ីនធឺណែត ពួកគេនៅតែអាចឆ្លើយតបបានតាមរយ:គេហទំព័ររបស់ការិយាល័យ</td></tr>
<tr><td>ថ្ងៃទី 26 ខែមិនា - ថ្ងៃទី 3 ខែមេសា ឆ្នាំ 2020</td><td>ការិយាល័យជំរឿននឹងផ្ញើរលិខិតរំលឹកទៅគ្រួសារដែលមិនទាន់បានឆ្លើយតប។</td></tr>
<tr><td>ថ្ងៃទី 1 ខែមេសា ឆ្នាំ 2020</td><td>នេះគឺជាថ្ងៃជំរឿនផ្លូវការប្រចាំឆ្នាំ2020!</td></tr>
<tr><td>ថ្ងៃទី 8 - ថ្ងៃទី 16 ខែមេសា ឆ្នាំ 2020</td><td>ការិយាល័យជំរឿននឹងផ្ញើលិខិតរំលឹកមួយច្បាប់ ព្រមទាំងសំណុំបែបបទជាក្រដាសមួយច្បាប់ផងដែរ។</td></tr>
<tr><td>ថ្ងៃទី 20 - ថ្ងៃទី 27 ខែមេសា ឆ្នាំ 2020</td><td>ការិយាល័យជំរឿននឹងផ្ញើប័ណ្ណប្រកាសរំលឹកជាលើកចុងក្រោយ។ ការចុះសហគមន៍របស់ពួកគេដើម្បីលើកទឹក</td></tr>
</table>

| | | |
|---|---|---|
| | ចិត្តប្រជាជនឲ្យមានទឹកចិត្តឆ្លើយតបនឹងជំរឿនបញ្ចប់នៅថ្ងៃទី 12 ខែឧសភា ឆ្នាំ 2020។ | ជំរឿនដោយប្រាប់ពីអាស័យដ្ឋានរបស់ពួកគេ។ |
| **ខែឧសភា - ខែកក្កដា ឆ្នាំ 2020 --- ដំណាក់កាលការក្រើនរំលឹកនិងតាមដានការមិនឆ្លើយតប** | | |
| **ខែឧសភា - កក្កដា ឆ្នាំ 2020** | ការិយាល័យជំរឿនបានបញ្ជូនបុគ្គលិកធ្វើជំរឿនចុះទៅជួបគ្រួសារដែលមិនបានផ្ញើសំណុំបែបបទរបស់ខ្លួនត្រឡប់មកវិញ។ នៅក្នុងតំបន់ដែលមាននិស្សិតមហាវិទ្យាល័យដែលនៅក្រៅទីធ្លាបរិវេណមហាវិទ្យាល័យជាច្រើននាក់ ដំណើរការនេះចាប់ផ្តើមលឿនមុនកាលកំណត់ជាងនៅក្នុងខែមេសា។ | លើកទឹកចិត្តឱ្យប្រជាពលរដ្ឋឆ្លើយតបទៅនឹងជំរឿនប្រសិនបើពួកគេមិនទាន់បានឆ្លើយតបនៅឡើយទេ។ *ពួកគេនៅតែឆ្លើយតបក្នុងអំឡុងពេលនេះនៅលើបណ្តាញ តាមទូរស័ព្ទ ឬដោយផ្ញើតាមប្រៃសណីយ៍ត្រលប់មកវិញនូវទម្រង់បែបបទជាក្រដាស។*<br><br>ឆ្លើយសំនួរផ្សេងៗដែលសមាជិកសហគមន មានចម្ងល់អំពីជំរឿន ហើយកាត់បន្ថយភាពភ័យខ្លាចអំពីមូលហេតុដែលបុគ្គលិកធ្វើជំរឿនអាចចុះទៅសួរសុខទុក្ខតាមគ្រួសារប្រសិនបើពួកគេមិនទាន់ បានឆ្លើយតប។ |
| | ទម្រង់បែបបទលើប្រព័ន្ធអ៊ីនធឺណែត និង កម្រងសំណួរជំរឿនសម្រាប់ការស្ទង់មតិនៅតែអាចរកបានដើម្បីឱ្យប្រជាជនឆ្លើយតប។ | |
| **ដំណាក់ការក្រោយនៃការធ្វើជំរឿន** | | |
| **ខែមិថុនា - ខែកញ្ញា ឆ្នាំ2020** | ការស្ទង់មតិក្រោយការចុះបញ្ជីដើម្បីវាស់ស្ទង់កំហុសនៃការរាប់ចំនួន (ប្រជាជនខកខានមិនបានរាប់ ឬរាប់ច្រើន ជាងម្តង) នៅក្នុងជំរឿនឆ្នាំ 2020។ | |
| **ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020** | ថ្ងៃផុតកំណត់សម្រាប់ការិយាល័យជំរឿនដើម្បីធ្វើរបាយការណ៍ចំនួនប្រជាជនសរុបទៅកាន់លោកប្រធានាធិបតីសម្រាប់គោលបំណងចែកចាយ។ | |

*អ្នកអាចស្វែងរកធនធានបន្ថែមអំពីជំរឿន រួមមានទាំងក្រដាស Fact សម្រាប់សមាជិកសហគមន៍ និង អង្គការផ្សេងៗតាមសហគមន៍តាមរយៈ: www.CountUsIn2020.org/resources។*